01642870

D363/1.1.1

## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញាអន្តរជាតិ
ភាសាដើម : អង់គ្លេស

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 26 / 12 / 2019
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ក្នុងវិធាន ៨០ និងបើកកិច្ចប្រជុំរៀបចំសវនាការ

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Brenda J. HOLLIS

សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Martin Greg KAROPKIN
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់
នៃសំណុំរឿង ០០៤/២

សហមេធាវី អោ អាន:
លោក មុំ លុដ្ឋ
លោក Richard ROGERS
លោក Göran SLUITER

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៣៩(៤), ៧៧(១៣)(ខ), ៨០(១) និង ៧៩[1] សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមស្នើអង្គជំនុំជម្រះសាលាដំបូង (i) ពន្យារពេលកំណត់ដែលមានរយៈពេល ១៥ថ្ងៃ សម្រាប់ដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន ដែលគាត់មានបំណងចង់កោះហៅនៅពេលជំនុំជម្រះ និង (ii) រៀបចំកិច្ចប្រជុំមួយដើម្បីរៀបចំសវនាការ។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីពិចារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ដែលសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសន្និដ្ឋានផ្នែកច្បាប់ខុសៗគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីររូប ក្រោយពីបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនទៅលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹង អោ អាន[2]។

3. អង្គបុរេជំនុំជម្រះបានពិចារណាជាឯកច្ឆន្ទថា បញ្ហាថាតើសហចៅក្រមស៊ើបអង្កេតមាន "បុព្វសិទ្ធិ" ដែរឬអត់ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា "គឺអាស្រ័យទៅលើថាតើ ការដែលសហចៅក្រមស៊ើបអង្កេតមិនបានគោរពទៅតាមនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា [...] បានគេចវេសដែរឬអត់ ពីឥទ្ធិពលពិតប្រាកដនៃគោលជំហរជាក់ស្តែង ដែលជាមូលដ្ឋាននៃប្រពន្ធ័គតិយុត្តិរបស់ អ.វ.ត.កទាំងមូល"[3] ជាមួយនឹង "គោលជំហរជាក់ស្តែង/បច្ចុប្បន្ន" ដែលធ្វើឲ្យ "ការស៊ើបអង្កេតត្រូវតែបន្ត"[4]។ ជាការបន្ថែម អង្គបុរេជំនុំជម្រះ ៖

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង")។

[2] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ")។ សហចៅក្រមស៊ើបអង្កេតមួយរូបបានចោទប្រកាន់ និងឲ្យបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចំណែកសហចៅក្រមស៊ើបអង្កេតមួយរូបផ្សេងទៀត បានលើកលែងចោទប្រកាន់ប្រឆាំងនឹងគាត់។

[3] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ១១២។

[4] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ១០៦ *យោង* សំណុំរឿង ០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១, កថាខណ្ឌ ២៧៤។

សង្កត់ធ្ងន់ជាឯកច្ឆន្ទថា គោលការណ៍ដែលជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរជាក់ស្តែង មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឲ្យគោលការណ៍ស្នូលនេះ ក្លាយទៅជាគ្មានន័យនោះទេ[5]។

4. អង្គបុរេជំនុំជម្រះមិនអាចឈានដល់មតិភាគច្រើនចាំបាច់តាមវិធាន ៧៧(១៣) ដើម្បីចេញ "សេចក្តីសម្រេច"បានឡើយ។ ចៅក្រមបីរូបបានសម្រេចតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ និងបានមោឃៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ[6] ចំណែកចៅក្រមពីររូបផ្សេងទៀតបានទុកជាមោឃៈនូវដីកាសម្រេចលើកលែងចោទប្រកាន់ ដោយមានការកែប្រែខ្លះ[7]។

5. អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ចៅក្រមអង្គបុរេជំនុំជម្រះពីររូប បានថ្លែងថា៖

ការដែលអង្គបុរេជំនុំជម្រះមិនអាចឈានទៅដល់សេចក្តីសម្រេច ដោយសំឡេងភាគច្រើនលើសលុប ដោយចៅក្រមយ៉ាងតិចបួនរូបនោះ មិនបានរារាំងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយសំណុំរឿង មិនឲ្យបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹង អោ អាន[8] នោះទេ។

6. ចៅក្រមអង្គបុរេជំនុំជម្រះពីររូប បានអនុមតិ "ឲ្យបញ្ជូន អោ អាន ទៅជំនុំជម្រះ ដូចមានចែងកំណត់នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលបានកែប្រែ" និងបានសម្រេចថា "អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹង ស្របតាមមូលដ្ឋាននៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)"[9]។

## III. ច្បាប់ជាធរមាន

---

[5] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ១១២។

[6] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ១៧០-៣០២ "យោបល់របស់ចៅក្រមជាតិ"។

[7] ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ,កថាខណ្ឌ ៣០៤-៦៣៣ "យោបល់របស់ចៅក្រមអន្តរជាតិ"។

[8] ឯកសារ **D359/24 & D360/33** យោបល់របស់ចៅក្រមអន្តរជាតិ, កថាខណ្ឌ ៦៨៧។

[9] **D359/24 & D360/33** យោបល់របស់ចៅក្រមអន្តរជាតិ, ផ្នែកសម្រេចសេចក្តី។

7. វិធាន ១(២) នៃវិធានផ្ទៃក្នុង ចែងថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ"។

8. វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ចែងថា៖

> សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម៤ (បួន)រូប យ៉ាងតិច។ សេចក្ដីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តដូចខាងក្រោម៖
>
> [...]
>
> ខ) ក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

9. វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ចែងថា៖

> អង្គជំនុំជម្រះសាលាដំបូង ទទួលបណ្ដឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេត ឬ តាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

10. វិធាន ៧៩(៧) នៃវិធានផ្ទៃក្នុងចែងថា៖

> ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តិទៅនៃ កិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការប្រជុំរៀបចំសវនាការ ប្រសិនបើយល់ឃើញថាចាំបាច់។ កិច្ចប្រជុំនោះត្រូវធ្វើឡើងជាសម្ងាត់លើកលែងតែអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្សេងពីនេះ។ គោលបំណងនៃការប្រជុំនេះ នឹងអនុញ្ញាតឲ្យមានការផ្លាស់ប្ដូរមតិយោបល់គ្នារវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការបឋម សវនាការនៃអង្គសេចក្ដី និងពិនិត្យឡើងវិញនូវរឿង

ក្តី ដោយអនុញ្ញាតឲ្យជនជាប់ចោទ លើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងរឿងក្តីនោះ រួមទាំងស្ថានភាពរូបកាយ និងស្មារតី។

11. វិធាន ៨០(១) នៃវិធានផ្ទៃក្នុង ចែងថា ក្នុងការរៀបចំសវនាការ៖

សហព្រះរាជអាជ្ញាត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង នូវបញ្ជីឈ្មោះសាក្សី រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិណាមួយដែលមានចែងក្នុងវិធាន ២៤(២) និងអ្នកជំនាញដែលខ្លួនមានបំណងកោះហៅ ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនឯកសារថតចម្លងមួយច្បាប់ទៅឲ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ ។

12. ជាចុងក្រោយ ពាក់ព័ន្ធទៅនឹងពេលវេលាកំណត់ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងចែងថា "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាច៖ ក-ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់ [...]"។

## IV. សារណា

13. ដោយហេតុថា អង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងភាគច្រើនលើសលប់នៅក្នុងផ្នែកសម្រេចសេចក្តីរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបញ្ជូន អោ អានទៅជំនុំជម្រះ "គោលជំហរបច្ចុប្បន្ន" កំណត់ថា រឿងក្តីនេះត្រូវបញ្ជូនទៅជំនុំជម្រះផ្អែកតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។ និយមន័យនៃពាក្យសហចៅក្រមស៊ើបអង្កេតក្នុងវិធាន ១(២) នៃវិធានផ្ទៃក្នុងរួមបញ្ចូល "ពួកគាត់ទាំងពីរបំពេញកិច្ចរួមគ្នា និង ចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ" ហើយវិធាន ៧៩(១) ក៏បានគាំទ្រការបំពេញកិច្ចនេះដែរ។ សរុបមក ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយ សហចៅក្រមស៊ើបអង្កេតម្នាក់ ដែលមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលប់នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ "ត្រូវ" ប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដូចក្នុងស្ថានភាពនៅទីនេះ។

14. ដោយសារកង្វះសំឡេងភាគច្រើនលើសលុប អង្គជំនុំជម្រះសាលាដំបូងពេលនេះត្រូវបានប្តឹងឲ្យទទួលយករឿងក្តីនេះ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដោយសំណុំរឿងនេះឥឡូវនេះត្រូវបញ្ជូនទៅអង្គជំនុំជម្រះ។ សំណុំរឿងដែលត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង

គឺដោយសារអង្គជំនុំជម្រះសាលាដំបូងត្រូវបានប្ដឹងឲ្យទទួលយកតាមវិធានផ្ទៃក្នុងនេះ វាមិនមែនការបញ្ជូនសំណុំរឿងនេះនោះទេ ដែលប្ដឹងទៅអង្គជំនុំជម្រះនោះ។

15. ទោះបីជាចៅក្រមនៅអង្គបុរេជំនុំជម្រះ ខ្វែងយោបល់គ្នាលើផ្នែកសម្រេចសេចក្ដីនៃដីកាដំណោះស្រាយនីមួយៗ ពួកគាត់បានឯកភាពជាឯកច្ឆ័ន្ទលើគោលការណ៍ដែលថា ក្នុងករណីមិនមានសេចក្ដីសម្រេចដោយសំឡេងភាគច្រើនលើសលប់ គោលជំហរបច្ចុប្បន្នដែលថា "ការស៊ើបអង្កេតត្រូវតែបន្ត" គឺជា "មុខងារសំខាន់មាននៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក"[10] និងជា "មូលដ្ឋាននិងកត្តាកំណត់"[11]។

16. វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងតំណាងឲ្យលក្ខណៈជាមូលដ្ឋាន និងជាកត្តាកំណត់នៃគោលជំហរបច្ចុប្បន្នទៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ក្នុងករណីដែលផ្នែកសម្រេចសេចក្ដីរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ខកខានមិនទទួលបានសំឡេងភាគច្រើនដែលតម្រូវចាំបាច់ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") គាំទ្រចំណុចនេះ ដោយបានសម្រេចថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[12]។

---

[10] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១០៦។

[11] ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១១២។

[12] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦៥ *យោង* ច្បាប់ អ.វ.ត.ក មាត្រា ២៣*ថ្មី*។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤)។ វិធានផ្ទៃ ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។ ខណៈដែលការរកឃើញនេះកើតចេញពីការពិភាក្សាលើសេណារីយ៉ូដែល ស.ច.ស ម្នាក់ ឬទាំងពីរនាក់បានបញ្ជូនបញ្ហានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ខ្វែងគ្នាទៅកាន់អង្គបុរេជំនុំជម្រះ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង លទ្ធផលអង្គសេចក្ដីអាចអនុវត្តបានស្មើគ្នាចំពោះស្ថានភាពបច្ចុប្បន្ន ដែលអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលប់ លើថាតើចៅក្រមណាមួយមានកំហុសក្នុងការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងរឿងទៅជំនុំជម្រះ។

17. ទោះបីជា អ.ជ.ត.ក ប្រើឃ្លា "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ" ដោយសារតែវាត្រូវបានដកស្រង់ផ្ទាល់ចេញពីច្បាប់ អ.វ.ត.ក ការបកស្រាយដ៏សមហេតុផលតែមួយគត់នៃឃ្លានេះ គឺថាដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបន្តទៅជំនុំជម្រះ - មិនមានន័យណាផ្សេងទៀត ដែលក្នុងនោះមានអ្វីមួយអាច "បន្តទៅមុខ" នៅដំណាក់កាលដែល អ.ជ.ត.ក កំពុងពិភាក្សានោះទេ គឺមានតែការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ខ្វែងគ្នា។

18. សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះត្រូវបានជូនដំណឹងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវបានណែនាំឲ្យបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដែលបានកែប្រែ) "សេចក្តីពិចារណា" និងសំណុំរឿងនៃរឿងក្តី ០០៤/២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សវនាការជំនុំជម្រះ។ ការណ៍នោះនឹងធ្វើឲ្យវិធាន ៨០(១) ដំណើរការ ដែលតម្រូវឲ្យ ស.ព.អ ដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួនទៅកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះក្លាយជាស្ថាពរ។ ដោយសារមិនមានបណ្តឹងឧទ្ធរណ៍លើផ្នែកសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ទេនោះ ស.ព.អ ពិចារណាយកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ជាកាលបរិច្ឆេទដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដែលបានកែប្រែ) ចូលជាស្ថាពរ។ ដូច្នេះ បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់គាត់ត្រូវដាក់នៅត្រឹមថ្ងៃទី៣ ខែមករា ឆ្នាំ២០២០។

19. អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ស.ព.អ ស្នើសុំការពន្យារពេលដប់ (១០) ថ្ងៃរហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលតម្រូវដោយវិធាន ៨០(១) នៃវិធានផ្ទៃក្នុង។ សំណើសុំពន្យារពេលនេះមានភាពចាំបាច់ដោយសារបន្ទុកការងារបច្ចុប្បន្នរបស់ ស.ព.អ ដែលពាក់ព័ន្ធទៅនឹងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ពីររបស់ យឹម ទិត្យ ទាក់ទងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ក៏ដូចជា ការត្រៀមរៀបចំឆ្លើយតបទៅនឹងទឡ្ហីករណ៍ជាង ១៨០០ នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលត្រូវដល់ពេលកំណត់ក្នុងខែកុម្ភៈ ឆ្នាំ២០២០ ក្នុងសំណុំរឿង ០០២/០២។ បន្ថែមលើនេះ មុខតំណែងមេធាវីជាន់ខ្ពស់ពីរនៅចំហរនៅឡើយ បន្ទាប់ពីបុគ្គលិកទាំងនោះបានចាកចេញក្នុងខែវិច្ឆិកា (រួមបញ្ចូលទាំងម្នាក់ដែលត្រូវបានចាត់ទទួលខុសត្រូវសំណុំរឿង ០០៤/២) និងបុគ្គលិកជាមេធាវីជាច្រើនទៀតបច្ចុប្បន្ននេះកំពុងឈប់សម្រាកតាមការគ្រោងទុកជាមុនក្នុងរយៈពេលយូ។ ហេតុដូច្នេះ ស.ព.អ ស្នើសុំពេលវេលា ១០ថ្ងៃ បន្ថែម ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដើម្បីឲ្យគាត់អាចធ្វើការ

ពិនិត្យ និងជ្រើសរើសដ៏មានអត្ថន័យពីសាក្សីជាង ៤៧០នាក់ ដែលបានកំណត់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានស្ដាពររបស់ ស.ព.អ។

20. អនុលោមតាវិធាន ៧៩(៧) នៃវិធានផ្ទៃក្នុង ស.ព.អ ក៏ស្នើសុំផងដែរ ឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់កាលវិភាគកិច្ចប្រជុំរៀបចំសវនាការ ដើម្បីសម្រួលដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ដោយរួមមានការកំណត់កាលបរិច្ឆេទសវនាការបឋម ឬសវនាការនៃអង្គសេចក្ដី និងការពិនិត្យរឿងក្ដីឡើងវិញ។

## V. ឧបាស្រ័យដែលស្នើសុំ

21. សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងពន្យារពេលកាលបរិច្ឆេទកំណត់ ១៥ថ្ងៃ តាមវិធាន ៨០(១) នៃវិធានផ្ទៃក្នុង ទៅដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ និងសុំឲ្យរៀបចំកិច្ចប្រជុំរៀបចំសវនាការ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

CO-PROSECUTORS CO-PROCUREURS E.C.C.C * C.E.T.C